00172277

C20/I/9

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| | |
|---|---|
| សំណុំរឿងលេខ: | ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០២) |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន | ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន: | មេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ |
| ភាសាដើម: | ខ្មែរ និង អង់គ្លេស |
| ប្រភេទឯកសារ: | សាធារណៈ |

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 21 / 03 / 2008
ម៉ោង (Time/Heure): 10.45 AM
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kossal

---

## សំណើសុំពន្យាពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន

---

**បញ្ជូនដោយ:**

**សហមេធាវីការពារក្តីរបស់អ្នកស្រី អៀង ធីរិទ្ធ**

លោកមេធាវី ផាត់ ពៅសីុង

កញ្ញា Diana ELLIS QC (ទីប្រឹក្សាច្បាប់)

**អ្នកទទួលឯកសារ:**

**ចៅក្រមនៃអង្គបុរេជំនុំជម្រះ**

លោក ប្រាក់ គឹមសាន

លោក ន៍យ ថុល

លោក ហួត វុទ្ធី

លោកស្រី Katinka LAHUIS

លោក Rowan DOWNING

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Robert PETIT

ឯកសារបានចំលងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 21 / 03 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: CHEA Kossal

00172278

C20/I/9

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០២)

## I. សេចក្តីផ្តើម និង អង្គហេតុពាក់ព័ន្ធ

1. នៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះបានសម្រេចកំណត់បើកសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្តោះអាសន្ន នៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ ("ហៅថាសេចក្តីសម្រេចពីការកំណត់ថ្ងៃសវនាការ")[1] ។

2. មុនពេលចេញសេចក្តីសម្រេចពីការកណត់ថ្ងៃបើកសវនាការ ប្រធានអង្គភាពគាំពារការការពារក្តីបានជូនដំណឹងដល់អង្គបុរេជំនុំជម្រះជាច្រើនលើកច្រើនសារថា កញ្ញា Diana Ellis សហមេធាវីបរទេសនឹងមិនមានលទ្ធភាពចូលរួមសវនាការលើបណ្តឹងឧទ្ធរណ៍ដែលគ្រោងធ្វើឡើងនៅទីក្រុងភ្នំពេញនាខែមេសាខាងមុខនេះបានទេ ដោយសារតែកញ្ញាជាប់កាតព្វកិច្ចវិជ្ជាជីវៈមួយយូរមកហើយនៅប្រទេសអង់គ្លេស ដែលអង្គភាពគាំពារការការពារក្តីបានជម្រាបរួចមកហើយ មុនពេលចាត់តាំងកញ្ញាជាសហមេធាវី ។

3. ប្រសិនបើសវនាការ ពិតជាត្រូវប្រព្រឹត្តទៅនៅថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៨ តាមការគ្រោងទុកមែននោះសហមេធាវីបរទេសរបស់អ្នកស្រី **អៀង ធីរិទ្ធ** នឹងមិនអាចចូលរួមបានទេ ។ ស្ថានការណ៍បែបនេះនឹងផ្ទុយពីសេចក្តីប៉ងប្រាថ្នារបស់អ្នកស្រី **អៀង ធីរិទ្ធ**។ ការបើកសវនាការក្នុងកាលៈទេសៈបែបនេះនឹងរំលោភបំពានលើសិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ។ ហេតុដូច្នេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គបុរេជំនុំជម្រះពន្យាពេលសវនាការ ។

## II. អង្គច្បាប់

4. វិធាន ២១ នៃវិធានផ្ទៃក្នុងចែងថា ជនជាប់ចោទមានសិទ្ធិ "ការពារដោយមេធាវីតាមការជ្រើសរើសរបស់ខ្លួន" ។ សិទ្ធិនេះក៏មានបញ្ញត្តិនៅក្នុងមាត្រា ១៣ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា[2] និងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្សអន្តរជាតិជាច្រើនទៀត[3] ។

---

[1] សេចក្តីសម្រេចពីការកំណត់ថ្ងៃបើកសវនាការរបស់អង្គបុរេជំនុំជម្រះ ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៨, ឯកសារលេខ C20/I/8 ។

[2] កិច្ចព្រមព្រៀងរវាងរដ្ឋាភិបាលកម្ពុជា និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទិននឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបង្កឡើងនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ។

[3] សូមមើលមាត្រា ១៤(៣)(ខ) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងមាត្រា ៦(៣)(គ) នៃអនុសញ្ញាសហគមន៍អឺរ៉ុបស្តីពីសិទ្ធិមនុស្ស ។

5. គោលការណ៍ជាមូលដ្ឋានស្តីពីសមភាពនៃគូភាគីនៃរឿងក្តីនៅក្នុងបរិបទនៃ អ.វ.ត.ក ចែងថាជនត្រូវចោទត្រូវការពារដោយសហមេធាវីពីររូប ដូចគ្នានឹងអយ្យការដែរ ។

## III. ឧឡ្លឹករណ៍

6. ដើម្បីធានាការពារដល់សិទ្ធិក្នុងការជ្រើសរើសមេធាវីការពារដោយខ្លួនឯង មេធាវីការពារយល់ឃើញថាអង្គបុរេជំនុំជម្រះមានកាតព្វកិច្ចពិចារណាពីលទ្ធភាពចូលរួមរបស់មេធាវីការពារ នៅក្នុងការសម្រេចបើកសវនាការ។ នៅក្នុងការពិភាក្សាក្រៅផ្លូវការស្តីពីលទ្ធភាពចូលរួមរបស់ភាគីពាក់ព័ន្ធ ទាំងអស់អង្គបុរេជំនុំជម្រះត្រូវបានជូនដំណឹងអំពីកាលបិរច្ឆេទវត្តមានរបស់សហមេធាវីបរទេស ។ មេធាវីការពារកត់សំគាល់ឃើញថា បញ្ហាដូចគ្នានេះបានកើតឡើងនៅក្នុងរឿងក្តីរបស់ លោក ខៀវ សំផន រួចមកហើយ ។ មេធាវីការពារក្តីសូមស្នើថា សិទ្ធិរបស់ជនត្រូវចោទដែលត្រូវការពារដោយ សហមេធាវីជាតិនិងសហមេធាវីបរទេស គប្បីយកមកពិចារណាឲ្យបានហ្មត់ចត់ ហើយការខកខានក្នុងការធ្វើបែបនេះនឹងនាំឲ្យមានការរំលោភសិទ្ធិទទួលបានសវនាការប្រកបដោយយុត្តិធម៌របស់អ្នកស្រី ដូចដែលបានលើកឡើងខាងលើ ។

7. ជាមួយគ្នានេះផងដែរ គោលការណ៍សមភាពនៃគូរភាគីលើកឡើងថា ជនត្រូវចោទត្រូវទទួលបានការការពារពីសហមេធាវីពីររូប ដូចគ្នានឹងអយ្យការដែលត្រូវបានតំណាងដោយសហព្រះរាជអាជ្ញាពីររូបដូច្នោះដែរ។

8. ក្នុងរឿងក្តីប្រឆាំងនឹងសហជនត្រូវចោទឈ្មោះ នួន ជា អង្គបុរេជំនុំជម្រះបានបង្កើតនូវយុត្តិសាស្ត្រមួយនៅក្នុងស្ថានភាពប្រហាក់ប្រហែលគ្នានេះដែរ ដោយបានផ្អាកសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដោយសារមូលហេតុមេធាវីបរទេសមិនអាចការពារកូនក្តីរបស់ខ្លួនបាននៅក្នុងតុលាការ ដោយសារតែមេធាវីបរទេសរូបនេះមិនទាន់បានធ្វើសច្ចាប្រណិធានជាមួយគណៈមេធាវីកម្ពុជានៅឡើយ។

9. សិទ្ធិរបស់ជនត្រូវចោទដែលត្រូវការពារដោយមេធាវីតាមការជ្រើសរើសរបស់ខ្លួន រួមមាន សិទ្ធិមានវត្តមានរបស់សហមេធាវីជាតិ និងសហមេធាវីបរទេសនៅក្នុងពេលសវនាការ។ មេធាវីការពារក្តីយល់ឃើញថា ការមានវត្តមាននៃមេធាវីបរទេសនៅពេលសវនាការ គឺដើម្បីផលប្រយោជន៍យុត្តិធម៌ផង និងដើម្បីសិទ្ធិទទួលបានការកាត់ក្តីប្រកបដោយយុត្តិធម៌របស់ជនត្រូវចោទផង ។

00172280

E20/I/9

០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ០២)

10. ក្នុងករណីនេះ មេធាវីការពារក្តីសូមស្នើថា ការពន្យារសវនាការដែលបានស្នើនេះ គឺមិនមានរយៈពេលវែងពេកទេ ហើយវាក៏ស្របតាមបំណងរបស់អ្នកស្រី **អៀង ធីរិទ្ធ** ដែរ ហេតុដូច្នេះសូមអង្គបុរេជំនុំជម្រះមេត្តាពិនិត្យ និងសម្រេចតាមការគួរ។

IV. **សេចក្តីសន្និដ្ឋាន**

11. យោងតាមមូលហេតុដូចដែលបានលើកឡើងខាងលើ មេធាវីការពារក្តីសូមសំណូមពរដោយគោរពឲ្យអង្គបុរេជំនុំជម្រះពន្យាសវនាការដែលបានគ្រោងរួចហើយនោះ រហូតដល់ថ្ងៃទី២១ ឬ ២២ ខែឧសភា ឆ្នាំ ២០០៨ ។

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០០៨

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

**មេធាវី ផាត់ ពៅស៊ាង**
សហមេធាវីរបស់ **អៀង ធីរិទ្ធ**

**Diana ELLIS QC**
ទីប្រឹក្សាច្បាប់របស់ **អៀង ធីរិទ្ធ**